ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៧៤១៧......អយក ប្រក

ចូលបញ្ជីលេខ

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ 2007

# ប្រកាស

## ស្ដីពី

## ការបង្កើតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

## នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

****

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្ដីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្ដមសិក្សា និងសិក្សាឯកទេស
- បានឃើញលិខិតលេខ ៤២១ សជណ.អវ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៤ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីករណីសុំប្ដូរឈ្មោះវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ ជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បានឃើញប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្ដីពីការបណ្ដុះបណ្ដាលថ្នាក់អនុបណ្ឌិត
- បានឃើញប្រកាសលេខ ៧០៦ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីការបំពេញបន្ថែមលើប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់អនុបណ្ឌិត
- បានឃើញសារាចរណែនាំលេខ ០៦ អយក.សរណន ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីការបើកឯកទេសថ្មី ដេប៉ាតឺម៉ង់ថ្មី មហាវិទ្យាល័យថ្មី និងការបើកសាខានៅតាមគ្រឹះស្ថានឧត្ដមសិក្សា
- បានឃើញលិខិតលេខ ៤២១ វបក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦ របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បានឃើញយោបល់របស់អគ្គនាយកដ្ឋានឧត្ដមសិក្សា៚

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Website: www.moeys.gov.kh

## ស ម្រេ ច

**ប្រការ ១.-**

អនុញ្ញាតឱ្យ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បើកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញដូចខាងក្រោម :

- ទេពកោសល្យអគ្គិសនី និងថាមពល
- ទេពកោសល្យព័ត៌មានវិទ្យា និងទូរគមនាគមន៍
- ទេពកោសល្យជនបទ
- ទេពកោសល្យឧស្សាហកម្ម និងមេកានិច
- ទេពកោសល្យគីមីចំណីអាហារ និងវិស្វកម្មគីមី
- ទេពកោសល្យសំណង់ស៊ីវិល ។

**ប្រការ ២.-**

លក្ខខណ្ឌជ្រើសរើសនិស្សិតឱ្យចូលរៀន ត្រូវគោរពតាមបទដ្ឋាន កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៣.-**

និស្សិតដែលរៀនចប់កម្មវិធីសិក្សា ហើយបានទទួលជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួល បានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់តាមមុខជំនាញ ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នឹងត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានភារកិច្ច រៀងៗខ្លួន អនុវត្ត និងប្រតិបត្តិតាមប្រកាសនេះ ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាព គតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ... ឆ្នាំ ២០០៦

បណ្ឌិត គ្រួ ផេង

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង.អយក
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
  " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចក្នុងប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ នា.ឧស